# កិច្ចតែងការបង្រៀន

- ❖ **កាលបរិច្ឆេទ** ថ្ងៃ ពុធ ទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០២៥
- ❖ **មុខវិជ្ជា** បុរេគណិត
- ❖ **ប្រធានបទ** បំណិនពិចារណាក្នុងសង្គម
- ❖ **សកម្មភាពគោល** ល្បែង
- ❖ **ចំណងជើង** ត្រាប់តាមអ្នកលក់ដូរ
- ❖ **ថ្នាក់កម្រិត** ខ្ពស់
- ❖ **រយៈពេល** ៣០នាទី

I. **វត្ថុបំណង**

- ➢ **វិជ្ជាសម្បទា** កុមារប្រាប់បានប្រាប់ពីសកម្មភាពនិងតម្រូវការរបស់អ្នកលក់ អ្នកទិញបាន បានត្រឹមត្រូវតាមរយៈការពិនិត្យសង្កេតនិងការបំផុសសំនួររបស់គ្រូ។
- ➢ **បំណិនសម្បទា** កុមារលេងល្បែងត្រាប់តាមអ្នកលក់ដូរដោយប្រើ ក្រដាសប្រាក់ ១០០រៀល ៥០០រៀល ១០០០រៀល ២០០០រៀល ៥០០០រៀលដែលត្រូវប្រគល់ និងអាប់មកវិញតាមចំនួន បានត្រឹមត្រូវតាមរយៈការអនុវត្តផ្ទាល់។
- ➢ **ចរិយាសម្បទា** ស្តាប់គ្នា យោគយល់ អត់ឱនអធ្យាស្រ័យដល់គ្នាទៅវិញទៅមកដោយសប្បាយរីករាយ។

II. **សម្ភារឧបទេស**

- ➢ **សម្ភារៈគ្រូ** ក្រដាសប្រាក់ ១០០រៀល ៥០០រៀល ១០០០រៀល ២០០០រៀល ៥០០០រៀល សម្ភារបាយឡុកបាយឡ
- ➢ **សម្ភារៈកុមារ** ក្រដាសប្រាក់ ១០០រៀល ៥០០រៀល ១០០០រៀល ២០០០រៀល ៥០០០រៀល សម្ភារបាយឡុកបាយឡ
- ➢ **ការរៀបចំ** កុមារអង្គុយរាងអក្សរ U

III. **ដំណើរការបង្រៀន**

| **សកម្មភាពគ្រូ** | **ខ្លឹមសារ** | **សកម្មភាពកុមារ** |
|---|---|---|
| | **ជំហានទី១ លំនឹងថ្នាក់** | |
| -គ្រូហៅឈ្មោះកុមារតាមក្រុម | -ការពិនិត្យអវត្តមាន | -កុមារឆ្លើយ |
| -ឲ្យកុមារទៅលាងដៃទាំងអស់គ្នា | -ការពិនិត្យអនាម័យ | -កុមារទៅលាងដៃទាំងអស់គ្នា |
| -ឲ្យកុមារធ្វើត្រាប់តាមមករា | -ប្រមូលអារម្មណ៍ | -កុមារធ្វើត្រាប់តាមមករា |
| | **ជំហានទី២ រំឭកមេរៀនចាស់** | |
| -សួរចំណងជើងមេរៀនចាស់ | -គំនូរគូសចម្លងលេខ៥ | -កុមារឆ្លើយ |
| | ☼ **ទំនាក់ទំនងមេរៀនថ្មី** | |
| -តើកូនសុំអ្វីម៉ាក់មកសាលារៀន ? | -លុយ........ | -កុមាររៀបរាប់ |
| | **ជំហានទី៣ មេរៀនថ្មី** | |
| -គ្រូបំផុសសំណួរទាក់ទងនិងការទៅផ្សារ | -បំផុសសំណួរ | -កុមារឆ្លើយ |
| -កូនធ្លាប់ទៅផ្សារជាមួយម៉ាក់ប៉ាទេ ? | -ធ្លាប់ | -កុមារឆ្លើយ |

| | | |
|---|---|---|
| -តើនៅក្នុងផ្សារកូនឃើញគេធ្វើអ្វីខ្លះ? | -លក់ដូរ | -កុមារឆ្លើយ |
| -អ្នកលក់ដូរកូនឃើញគេលក់អ្វីខ្លះ? | -ត្រី បន្លែ ផ្លែឈើ | -កុមារឆ្លើយ |
| -តើអ្នកទិញគេទិញអ្វីខ្លះ?ហើយគេយកអ្វីទៅទិញ? | -លុយ | -កុមារឆ្លើយ |
| -គ្រូបង្ហាញក្រដាសប្រាក់១០០រៀល ៥០០រៀល ១០០០រៀល ២០០០រៀល ៥០០០រៀលឱ្យកុមារមើលនិងប្រាប់ឈ្មោះ(បើកុមារមិនស្គាល់គ្រូប្រាប់) | -បង្ហាញក្រដាសប្រាក់១០០រៀល ៥០០រៀល ១០០០រៀល ២០០០រៀល ៥០០០រៀល | -កុមារប្រាប់ឈ្មោះ |
| -គ្រូបង្ហាញសម្ភារសម្រាប់អ្នកលក់ ឱ្យកុមារប្រាប់ឈ្មោះម្តងមួយៗ | -បង្ហាញសម្ភារ | -កុមារប្រាប់ឈ្មោះម្តងមួយៗ |
| -គ្រូបែងចែកកុមារជាពីរក្រុម ១ក្រុមធ្វើជាអ្នកលក់ ១ក្រុមទៀតធ្វើជាអ្នកទិញតាមការស្ម័គ្រចិត្តរបស់កុមារ | -បែងចែកកុមារជាពីរក្រុម | -កុមារស្តាប់ |
| -គ្រូចែកសម្ភារទៅតាមអ្នកលក់និងអ្នកទិញរួចណែនាំពីរបៀបលេង | -ចែកសម្ភារទៅតាមអ្នកលក់និងអ្នកទិញ | -ស្តាប់ អនុវត្ត |
| -គ្រូឱ្យកុមារអនុវត្ត<br>+ក្រុមអ្នកលក់ពិភាក្សាបែងចែកសម្ភារគ្នាយកទៅរៀបចំដាក់លក់ឱ្យមានសណ្តាប់ធ្នាប់ ទៅតាមកន្លែងលក់ឥវ៉ាន់នីមួយៗ រួចលក់<br>+ក្រុមអ្នកលក់ដើរមើលឥវ៉ាន់តាម តាមកន្លែងលក់នីមួយៗ រួចចូលទិញអ្វីដែលខ្លួនចង់ទិញ<br>+អ្នកទិញសួរតម្លៃឥវ៉ាន់ដែលចង់ទិញ និងចរចាតម្លៃជាមួយអ្នលក់<br>+ត្រូវរូវតម្លៃគ្នាហើយ អ្នកលក់វេចខ្ចប់ អ្នកទិញប្រគល់ក្រដាសប្រាក់ តាមតម្លៃរបស់ឥវ៉ាន់នីមួយៗ ទៅវិញទៅមកដោយទឹកមុខរីករាយដាក់គ្នា(គ្រូសម្របសម្រួលដំណើរការលេងរបស់កុមារដោយជម្រុញលើកទឹកចិត្តការប្រគល់ក្រដាសប្រាក់មានការអាប់ឱ្យគ្នាទៅវិញទៅមក) | -អនុវត្ត | -កុមារអនុវត្ត |
| -គ្រូសរសើរនិងលើកទឹកចិត្តកុមារ | -លើកទឹកចិត្ត | -ស្តាប់ |
| -បំផុសរកចំណងជើងមេរៀន | -បុរេគណិត ល្បែង ត្រាប់តាមអ្នកលក់ដូរ | -កុមារឆ្លើយ |
| | **ជំហានទី៤ ពង្រឹងចំណេះដឹង** | |
| -តើអំបាញ់មិញកូនបានរៀនបុរេគណិតអំពីអ្វី? | -បុរេគណិត ល្បែង ត្រាប់តាមអ្នកលក់ដូរ | -កុមារឆ្លើយ |
| -ឲ្យកុមារឡើងរើសក្រដាសប្រាក់ ២ឬ៣នាក់? | | -កុមារឡើងរើស ក្រដាសប្រាក់ ២ឬ៣នាក់ |

| | | |
|---|---|---|
| -ចាំ! កូនៗទាំងអស់គ្នាធ្វើបានល្អណាស់ ថ្ងៃក្រោយធ្វើឲ្យបានល្អជាងនេះណាំ..! ទៅផ្ទះវិញប្រាប់ម៉ាក់ប៉ាថាកូនស្គាល់ក្រដាសប្រាក់ផងណា។ | **ជំហានទី៥ បណ្តាំផ្ញើ**<br>-លើកសរសើររួម ឬក្រុមនិងផ្តាំផ្ញើ | -ស្តាប់ |

សុខារាម ថ្ងៃទី២៦ ខែ កុម្ភៈ ឆ្នាំ ២០២៥
គ្រូបន្ទុកថ្នាក់

តាន់ រចនា

**បានឃើញ និងឯកភាព**
នាយិកាសាលា